# *របាយការណ៍*
# *ស្តីពី*
# *លទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀន ខែមករា ឆ្នាំ២០១១*
# *និងទិសដៅការងារត្រួតពិនិត្យគ្រឿងញៀន ខែកុម្ភៈ ឆ្នាំ២០១១*
# *(០១/០១/២០១១-៣១/០១/២០១១)*

**ខែមករាឆ្នាំ២០១១ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានបន្តយកចិត្តទុកដាក់អនុវត្តតាមទិសដៅ ពហុវិស័យ ដែលបានដាក់ចេញកាលពីខែធ្នូឆ្នាំ២០១០កន្លងមក សំដៅរួមចំណែករក្សាសន្តិសុខ សណ្តាប់ធ្នាប់ សង្គម ស្របតាមកម្មវិធីនយោបាយជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល សម្រាប់នីតិកាលទី៤នៃរដ្ឋសភា ។ ជាក់ស្តែង សកម្មភាពនិងលទ្ធផលការងារដែលអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានខិតខំអនុវត្តក្នុងខែ មករានេះ ជាអាទិ៍មាន ៖**

## I. *សភាពការណ៍គ្រឿងញៀន*

### *១.សភាពការណ៍គ្រឿងញៀនអន្តរជាតិ*

**តាមរយៈកិច្ចប្រជុំប្រមុខភ្នាក់ងារអនុវត្តច្បាប់គ្រឿងញៀនថ្នាក់ជាតិនៅតំបន់អាស៊ី-ប៉ាស៊ីហ្វិក លើកទី៣៤** (*HONLEA*)**បានឲ្យដឹងពីការកើនឡើងនូវការដាំដុះអាភៀននៅប្រទេសអាហ្វហ្គានីស្ថាន និងការដាំដុះអាភៀន ការ ផលិតគ្រឿងញៀនសំយោគ***ATS***នៅប្រទេសមីយ៉ាន់ម៉ា សម្រាប់នាំចេញទៅទីផ្សារគ្រឿងញៀនក្នុងតំបន់ ហើយ ការចរាចរសារធាតុគីមីផ្សំចេញពីប្រភពប្រទេសឧស្សាហកម្មគីមីក៏កាន់តែមានលក្ខណៈស្មុគ ស្មាញឡើង ។ ទន្ទឹម នេះ ក៏មាននិន្នាការថ្មីៗមួយចំនួនទៀតត្រូវបានកត់សម្គាល់ផងដែរ នោះគឺការចម្រាញ់ ការចរាចរប្រេងសាហ្វ្រុល ការចម្រាញ់យកសារធាតុផ្សីដូ-អេហ្វេទ្រីន ពីក្នុងឱសថព្យាបាលជម្ងឺផ្តាសាយ ការចរាចរនិងការប្រើប្រាស់ថ្នាំ កេតាមីន និងសារធាតុញៀនថ្មីគឺ** *4-MMC(4-Methyl Meth Cathinone)* **ក្នុងខណៈដែលអ្នកញៀនពពួក***ATS* **កំពុងនៅមានកង្វះខាតផ្នែកសេវាកម្មព្យាបាលនៅឡើយ ។**

អង្គប្រជុំបានបង្ហាញពីការបារម្ភចំពោះក្រុមឧក្រិដ្ឋជន នៃបណ្ដាប្រទេសអាហ្វ្រិកខាងលិច ដែលកំពុងធ្វើសកម្មភាពសម្អាតប្រាក់ដែលបានមកពីជំនួញគ្រឿងញៀនខុស

ច្បាប់ តាមរយៈការជួលអតិថិជនក្រីក្រឲ្យបើកលេខគណនីតាមធនាគារ ក្នុងគោលដៅផ្ទេរប្រាក់ និងសម្អាតប្រាក់
កខ្វក់របស់ពួកគេ ។

*២. សភាពការណ៍គ្រឿងញៀននៅកម្ពុជា*

ដោយមានការកើនឡើងនូវការផលិតប្រភេទគ្រឿងញៀនសំយោគ*ATS* នៅតំបន់ត្រីកោណមាស ដូច្នេះ សកម្មភាពចរាចរគ្រឿងញៀនពីតំបន់ត្រីកោណមាស ចូលមកកម្ពុជាតាមបណ្ដាខេត្តនៅតាមគល្លាសានប្រទេស នៅ តែជាបញ្ហាគួរកត់សម្គាល់ ។ ជាមួយនេះដែរ ពួកឧក្រិដ្ឋជនគ្រឿងញៀននៅតែបន្តប្រើគ្រប់ល្បិចកល ក្នុងការដឹកជញ្ជូនសារធាតុគីមីផ្សំគ្រឿងញៀនសំយោគ*ATS* ដូចជា អេហ្វេឌ្រីន(*Ephedrine*) និង ផ្សឺដូ-អេហ្វេ ឌ្រីន*(Pseudo-Ephedrine)* ឆ្ពោះទៅកាន់គោលដៅផលិតនានា ។ ជាក់ស្ដែងនៅក្នុងខែមករានេះ ពួក ឧក្រិដ្ឋជន បានប្រើវិធីលាក់បង្កប់សារធាតុអេហ្វេឌ្រីននៅក្នុងកញ្ចប់បញ្ញើរបស់ក្រុមហ៊ុនសេវាកម្មដឹកជញ្ជូនរហ័ស ពីប្រទេសឥណ្ឌាឆ្លងកាត់ប្រទេសកម្ពុជាចំនួនពីរលើក
និងធ្វើការដឹកជញ្ជូនឱសថដែលមានផ្ទុកសារធាតុផ្សឺដូ-អេ ហ្វេឌ្រីន(*Pseudo-Ephedrine*)ពីប្រទេសកូរ៉េខាងត្បូងឆ្លងកាត់ប្រទេសវៀតណាម
ចូលមកកម្ពុជាតាមច្រកកំពង់ផែ សមុទ្រអន្ដរជាតិក្រុងព្រះសីហនុ(ខេត្តព្រះសីហនុ) ឆ្ពោះមករាជធានីភ្នំពេញរួចធ្វើការបំបែកទៅតាមគោលដៅស្ដុក ទុកមួយចំនួន ។ នេះជាការដឹកជញ្ជូនលើកទី២(ថ្ងៃទី២៧ខែធ្នូឆ្នាំ២០១០) បន្ទាប់ពីការដឹកជញ្ជូនពីប្រទេសកូរ៉េខាងត្បូងដូចគ្នាដែរ
ដោយឆ្លងកាត់ប្រទេសថៃចូលមកកម្ពុជាតាមច្រកប៉ោយប៉ែតខេត្តបន្ទាយមានជ័យ
កាលពីថ្ងៃ ទី២២ខែសីហាឆ្នាំ២០១០ ។

## II. លទ្ធផលការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន

*ការងារដឹកនាំអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន*

ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានបន្តយកចិត្តទុកដាក់ លើកកម្ពស់វិធានការពហុវិស័យក្នុងការត្រួតពិនិត្យគ្រឿងញៀនជាអាទិ៍ ៖

-ការបញ្ច្រាបកម្មវិធីអប់រំបង្ការពីគ្រឿងញៀន នៅក្នុងទិវា៧មករា២០១១ នៅខេត្តបន្ទាយមានជ័យ ។

-ការណែនាំឲ្យរៀបចំយន្តការបង្កើត “សាលារៀនពណ៌បៃតងគំរូគ្មានគ្រឿងញៀន” ។

-ការណែនាំឲ្យបន្តកិច្ចសហការបង្កើតមិត្តប័ណ្ណអន្តរក្រសួងសម្រាប់ផ្សព្វផ្សាយអប់រំ នៅតាមគោលដៅ ដែលងាយប្រឈមគ្រោះថ្នាក់ខ្ពស់ ។

-

ការណែនាំឲ្យបង្កើតក្រុមការងាររៀបចំផែនការសកម្មភាពពាក់ព័ន្ធនឹងគម្រោងទ្វេភាគីកម្ពុជា-កូរ៉េ (រយៈ ពេលវែង)ស្តីពីកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀន ។

-ការណែនាំឲ្យរៀបចំផែនការជាតិស្តីពី ការត្រួតពិនិត្យគ្រឿងញៀន ឆ្នាំ២០១១-២០១៥ ។

-

ការណែនាំឲ្យរៀបចំបូកសរុបលទ្ធផលនៃការអនុវត្តន៍ផែនការប្រតិបត្តិត្រួតពិនិត្យគ្រឿងញៀនឆ្នាំ២០១០ នៅខេត្តបន្ទាយមានជ័យ ដើម្បីដកស្រង់បទពិសោធន៍សម្រាប់អនុវត្តទូទាំងប្រទេស ។

-ការណែនាំឲ្យរៀបចំកម្មវិធី និង គោលការណ៍ណែនាំសំរាប់មណ្ឌលបណ្តោះអាសន្ន អប់រំ ព្យាបាលនិងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ។

-ការណែនាំឲ្យធ្វើការបូកសរុបទិន្នន័យព័ត៌មានគ្រឿងញៀន តាមគោលការណ៍ប្រៀបសមរភូមិប្រឆាំង បទល្មើសគ្រឿងញៀន ។

-ការណែនាំ ជំរុញឲ្យធ្វើការសរុបលទ្ធផលនៃការអនុវត្តន៍តាមអនុសាសន៍របស់សម្តេចអគ្គមហាសេនា បតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានថ្លែងក្នុងឱកាសបិទសន្និ- បាតបូកសរុបលទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀនឆ្នាំ២០០៩ និងលើកទិសដៅការងារឆ្នាំ២០១០ ។

-ការណែនាំឲ្យតម្លើងបញ្ជីករណីបទល្មើសដែលបានបង្ក្រាបឆ្នាំ២០១០ ដើម្បីឲ្យដឹងពីចំនួនដែលបាន បង្ក្រាបនិងបានបញ្ជូនទៅតុលាការជម្រះក្តី ។ល។

*១. ការកាត់បន្ថយតម្រូវការគ្រឿងញៀន*

អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានដឹកនាំនិងសហការសម្របសម្រួលជាមួយក្រសួង-ស្ថាប័ន គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត អង្គការមិនមែនរដ្ឋាភិបាលនិងវិស័យឯកជន ធ្វើការផ្សព្វផ្សាយអប់រំលើកកម្ពស់ការយល់ដឹងជាសាធារណៈអំពីច្បាប់ និងគ្រោះថ្នាក់នៃគ្រឿងញៀន តាមរយៈសកម្មភាព ដូចជា ៖

-ការផ្តល់បទសម្ភាសន៍តាមកម្មវិធីប្រចាំខែនៅស្ថានីយទូរទស្សន៍*CTN* ។

-ការចូលរួមជាវាគ្មិនក្នុង“វេទិការអ្នកស្តាប់វិទ្យុអាស៊ីសេរី” ជាលក្ខណៈផ្សាយបន្តផ្ទាល់នូវសំណួរចម្លើយ ។

-ការបញ្ច្រាបកម្មវិធីអប់រំបង្ការគ្រឿងញៀន នៅក្នុងទិវា៧មករា២០១១ នៅខេត្តបន្ទាយមានជ័យ ដែល មានប្រជាជន/មហាជន ចូលរួមប្រមាណ ១.000 នាក់ ។

-ការបង្កើតSTICKERអន្តរក្រសួងសម្រាប់ផ្សព្វផ្សាយអប់រំពីបញ្ហាគ្រឿងញៀន អាចុធជាតិផ្ទុះ ជួញដូរគេច និងមេរោគអេដស៍/ជម្ងឺអេដស៍ នៅតាមបណ្តាគោលដៅដែលងាយប្រឈមខ្ពស់នឹងគ្រោះថ្នាក់ ។

-ការជួយធ្វើអន្តរាគមន៍ឲ្យសមាគមយុវជនខ្មែរ បានធ្វើសកម្មភាពអប់រំបង្ការគ្រឿងញៀននៅតាមបណ្តា គោលដៅងាយប្រឈមខ្ពស់នឹងគ្រោះថ្នាក់នៅ រាជធានីភ្នំពេញ ខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ និងខេត្តសៀមរាប ។

សកម្មភាពខាងលើ គួបផ្សំការងារផ្សព្វផ្សាយអប់រំប្រចាំខែរបស់គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀន រាជធានី-ខេត្តនានា គឺមានមហាជន/ប្រជាជនចូលរួមសរុបចំនួន ៣.៧៧១ នាក់ ។

*២. ការកាត់បន្ថយការផ្គត់ផ្គង់គ្រឿងញៀន*

ខែមករាឆ្នាំ២០១១ បង្ក្រាបបទល្មើសបាន *៣៣*ករណី[១], ឃាត់ខ្លួនជនល្មើស *៦៦*នាក់ (ប្រុស៥១ នាក់ ស្រី១៥នាក់) ក្នុងនោះ ជនជាតិខ្មែរ *៥៦*នាក់(ប្រុស៤៤នាក់ ស្រី១២នាក់), វៀតណាម *៧*នាក់ (ប្រុស៤នាក់ ស្រី៣នាក់), ឡាវ *២*នាក់(ប្រុស), បារាំង *១*នាក់(ប្រុស) ។ វត្ថុតាងចាប់យករួមមាន ៖

-មេតំហ្វេតាមីនគ្រាប់(*WY*) ៨.៤៤៩ គ្រាប់ -មេតំហ្វេតាមីន*ICE* ២១២,៩៦ ក្រាមនិង២កញ្ចប់តូច

-អ៊ិចស្តាស៊ី ៧ គ្រាប់ -កញ្ឆា ១១៤ ដើម = ២២,៨ ម៉ែត្រក្រឡា

-សារធាតុអេហ្វេឌ្រីន ៣.0៤៦ ក្រាម -ប្រេងម្រះព្រៅភ្នំ ១១ ប៊ីដុង = ៤៣៤ គ.ក្រ

ព្រមទាំង រថយន្ត៧គ្រឿង, ម៉ូតូ៤គ្រឿង និងឧបករណ៍វេចខ្ចប់និងប្រើប្រាស់គ្រឿងញៀនមួយចំនួន ។

ដោយឡែក សារធាតុគីមីផ្សំ ដែលមានច្បាប់អនុញ្ញាតឲ្យនាំចូលដោយក្រសួងមានសមត្ថកិច្ច ប្រចាំខែ មករា ឆ្នាំ២០១១ នេះ សរុបមានចំនួន ៤៥៧.១៥0 គីឡូក្រាម និង ២៥0 លីត្រ ។

*៣. ការព្យាបាល ស្តារនីតិសម្បទា និង ការកាត់បន្ថយគ្រោះថ្នាក់ នានា*

*.ការព្យាបាល ស្តារនីតិសម្បទា អ្នកញៀនគ្រឿងញៀន*

មណ្ឌលបណ្តោះអាសន្នសម្រាប់អប់រំបន្សាបព្យាបាលនិងស្តារនីតិសម្បទាអ្នកញៀន គ្រឿងញៀន "ឱកាស

ខ្ញុំ”របស់សាលារាជធានីភ្នំពេញ បាននឹងកំពុងបន្តការសាងសង់អគារស្នាក់នៅមួយខ្នងសម្រាប់ស្ត្រីដែលរងគ្រោះដោយសារគ្រឿងញៀន ។

ជាមួយនេះដែរ ដើម្បីចូលរួមចំណែកក្នុងការងារបង្ការទប់ស្កាត់គ្រោះថ្នាក់ដែលបណ្តាលមកពីការប្រើ បំពានគ្រឿងញៀនអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនបាន ៖

-រៀបចំសិក្ខាសាលាផ្សព្វផ្សាយអំពី “កិច្ចដំណើរការ និង វិធីសាស្ត្រក្នុងការប៉ាន់ប្រមាណពីចំនួនអ្នកប្រើ ប្រាស់គ្រឿងញៀននៅកម្ពុជា” កាលពីថ្ងៃទី២៨ខែធ្នូឆ្នាំ២០១០ នៅសណ្ឋាគារកាំបូឌីយ៉ាណា ដើម្បីជាមូលដ្ឋានក្នុងការរៀបចំផែនការយុទ្ធសាស្ត្រនិងសកម្មភាពនានាឆ្លើយតបទៅនឹងគោលដៅការងារប្រយុទ្ធ ប្រឆាំងគ្រឿងញៀន ។ សិក្ខាសាលានេះមានការអញ្ជើញចូលរួមពីមន្ត្រីជំនាញនៃក្រសួង-ស្ថាប័នពាក់ព័ន្ធ គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី/ខេត្ត អង្គការអន្តរជាតិ អង្គការមិនមែនរដ្ឋាភិ បាលពាក់ព័ន្ធ សរុបមានចំនួន ៨២ នាក់ ។

-កិច្ចប្រជុំផ្សព្វផ្សាយពី “លទ្ធផលនៃការអង្កេតតាមដានចំណោះដឹងស្តីពីជម្ងឺអេដស៍ និងការប្រព្រឹត្តផ្លូវភេទ នៅប្រទេសកម្ពុជាឆ្នាំ២០១០” កាលពីថ្ងៃទី៣០ខែធ្នូឆ្នាំ២០១០ នៅសណ្ឋាគារណាហ្គាវើល ដែលរៀបចំដោយមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជម្ងឺអេដស៍ សើស្បែក និងកាមរោគ នៃក្រសួងសុខាភិបាល សរុប មានចំនួន ២០០ នាក់ ។

-បានចូលរួមក្នុងសិក្ខាសាលា “ពិគ្រោះយោបល់លើកផែនការឆ្លើយតបទៅនឹងលទ្ធផលអង្កេតក្រុមយុវ-វ័យដែលប្រឈមខ្ពស់នឹងគ្រោះថ្នាក់” កាលពីថ្ងៃទី៣០-៣១/១២/២០១០ នៅសណ្ឋាគារ*Imperial Garden* ដែលរៀបចំដោយក្រសួងអប់រំយុវជននិងកីឡា ក្រោមការឧបត្ថម្ភរបស់អង្គការ*UNFPA* ដែលមានតំណាងមកពីក្រសួង-ស្ថាប័នពាក់ព័ន្ធ តំណាងរាជធានី-ខេត្តទាំង២៤ និងអង្គការមិនមែនរដ្ឋាភិបាលមួយចំនួនចូលរួមសរុបមានចំនួន ៨៨ នាក់ ។

-បានចូលរួមក្នុងសិក្ខាសាលាថ្នាក់ជាតិ “ស្តីពីសារសំខាន់នៃគោលនយោបាយគ្រឿងស្រវឹង” ដែលរៀបចំដោយមជ្ឈមណ្ឌលប្រជាពលរដ្ឋដើម្បីអភិវឌ្ឍន៍និងសន្តិភាព នៅសាលប្រជុំមន្ទីរពេទ្យកុមារជាតិ ដែល

---

(១)នៅក្នុងរបាយការណ៍ខែមករា ២០១១ របស់មន្ទីរប្រឆាំងគ្រឿងញៀន មាន៣៤ករណី, ជនល្មើស ៧៣ នាក់ ស្រី ១៦ នាក់ ប៉ុន្តែរបាការណ៍ខែមករា២០១១ របស់អគ្គលេខាធិការដ្ឋាន អជបគញ មានតែ ៣៣ ករណី ជនល្មើស ៦៦ នាក់ប៉ុណ្ណោះ អាស្រ័យដោយ ១ករណីឱសថដែលមានសារធាតុផ្សំជួអេហ្វេឌ្រីន ដែលបង្ក្រាបកាលពីថ្ងៃទី២៧ខែធ្នូឆ្នាំ២០១០ ត្រូវបានដាក់ បញ្ចូលទៅក្នុងរបាយការណ៍ប្រចាំខែធ្នូ ឆ្នាំ ២០១០ រួចហើយ ។

មានការអញ្ជើញចូលរួមពីតំណាងក្រសួងសុខាភិបាល ក្រសួងព័ត៌មាន ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ក្រសួងកិច្ចការនារី ការិយាល័យនគរបាលចរាចរណ៍ តំណាងកងរាជ អាវុធហត្ថ តំណាងអង្គការសង្គមស៊ីវិលនានា សរុបចំនួន ៧០ នាក់ ។

-បានអនុញ្ញាតឲ្យអង្គការមិត្តសម្លាញ់ អនុវត្តកម្មវិធីម្ជុល/ស៊ីរ៉ាំង នៅតាមបណ្តាគោលដៅងាយប្រឈម ខ្ពស់នឹងគ្រោះថ្នាក់មួយចំនួននៅក្នុង ខណ្ឌចំការមន ខណ្ឌ៧មករា ខណ្ឌដូនពេញ ខណ្ឌដង្កោ ខណ្ឌ មានជ័យ រាជធានីភ្នំពេញ ។

-កិច្ចប្រជុំថ្ងៃទី១៤ ខែមករា ឆ្នាំ២០១១ ដែលរៀបចំឡើងដោយអង្គការ*UNODC* នៅសណ្ឋាគារសាន់វ៉េ ដើម្បីពិភាក្សាអំពី "វិធានការលើកកម្ពស់គុណភាពកម្មវិធីព្យាបាលអ្នកញៀនគ្រឿងញៀនតាមសហ-គមន៍" និងដើម្បីត្រៀមរៀបចំសិក្ខាសាលាថ្នាក់ជាតិ ស្តីពី "កម្មវិធីកាត់បន្ថយគ្រោះថ្នាក់នៅកម្ពុជា" នៅក្នុងខែកុម្ភៈឆ្នាំ២០១១ ដែលមានការចូលរួមពី ក្រសួងសុខាភិបាល ក្រសួងអប់រំយុវជននិងកីឡា ក្រសួងសង្គមកិច្ចអតីតយុទ្ធជននិងយុវនីតិសម្បទាខេត្តបន្ទាយមានជ័យ អង្គការ*UNODC, KHANA, FI, FHI, WHO, UNAID, AUSaid* អង្គការមិត្តសម្លាញ់ សរុបមានអ្នកចូលរួមចំនួន ៣០ នាក់ ។

*៤. ការពង្រឹងសមត្ថភាពលើការងារអនុវត្តច្បាប់*

ដើម្បីលើកកម្ពស់សមត្ថភាពអនុវត្តច្បាប់ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនបានបន្តកិច្ចសហការ ជាមួយអង្គការដៃគូ(KHANA) ក្នុងការបើកវគ្គបណ្តុះបណ្តាលមន្ត្រីអនុវត្តច្បាប់នៅរាជធានីភ្នំពេញស្តីពីការងារត្រួតពិនិត្យគ្រឿងញៀន និងការកាត់បន្ថយគ្រោះថ្នាក់ កាលពីថ្ងៃទី១១-១២ខែមករាឆ្នាំ២០១១ នៅសាលារាជធានី ភ្នំពេញ ដែលមានមន្ត្រីអនុវត្តច្បាប់ចូលរួមសរុបចំនួន ២៦៦ នាក់ ។

ជាមួយនេះ ដើម្បីឲ្យវគ្គបណ្តុះបណ្តាលខាងលើកាន់តែទទួលបានគុណភាព អាជ្ញាធរជាតិប្រយុទ្ធប្រឆាំង គ្រឿងញៀន បានអញ្ជើញមន្ត្រីជំនាញមកពីក្រសួងពាក់ព័ន្ធ ជាអាទិ៍ ក្រសួងសុខាភិបាល អាជ្ញាធរជាតិប្រយុទ្ធ នឹងជម្ងឺអេដស៍ គណៈកម្មការអេដស៍នៃក្រសួងមហាផ្ទៃ បណ្ឌិត្យសភានគរបាលកម្ពុជា មកចូលរួមក្នុងការរៀប ចំកម្មវិធីបង្រៀនដើម្បីឲ្យកាន់តែមានភាពសុក្រឹតថែមទៀត និងបាន ៖

-ផ្តល់វិញ្ញាបនបត្របញ្ជាក់ការសិក្សាដល់សិក្ខាកាម ចំនួន៣៦រូប(ស្រី៣រូប) ដែលបានបញ្ចប់វគ្គបណ្តុះ បណ្តាល "ស្តីពីការត្រួតពិនិត្យគ្រឿងញៀនដោយប្រព័ន្ធកុំព្យូទ័រ" តាមការស្នើសុំរបស់ស្នងការដ្ឋាននគរបាល ខេត្តសៀមរាប ។

-បានចាត់តាំងមន្ត្រីនៃអគ្គលេខាធិការដ្ឋាន អជបគញ ចំនួន ៣ រូប ចុះទៅសហការជាមួយស្នងការ ដ្ឋាននគរបាលខេត្តកណ្តាល

ដើម្បីធ្វើការសិក្សាស្រាវជ្រាវប្រមូលព័ត៌មានទាក់ទងនឹងការចរាចរ ការប្រើប្រាស់សារធាតុគីមីផ្សំ ។

-បានចាត់តាំងមន្ត្រីនៃអគ្គលេខាធិការដ្ឋាន អជបគញ ១ រូប ធ្វើជាចំណុចកណ្តាល(*FocalPoint*) សម្រាប់ទំនាក់ទំនងការងារជាមួយក្រុមការងារសម្របសម្រួល វៃន-កម្ពុជា(*CWCU*)នៃរដ្ឋបាលព្រៃឈើ ។

ដោយឡែក ខេត្តក្រចេះបានជួបប្រជុំជាមួយការិយាល័យប្រឆាំងបទល្មើសគ្រឿងញៀននៃកងទ័ពការពារព្រំដែនលេខ៨០១ខេត្តប៊ិញភឿក(ប្រទេសវៀតណាម) កាលពីថ្ងៃទី២៨ខែធ្នូឆ្នាំ២០១០ នៅច្រកទ្វារអន្តរជាតិ (ត្រពាំងស្រែ(កម្ពុជា) និងច្រកហ័រលឺ(វៀតណាម) ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការក្នុងការត្រួតពិនិត្យគ្រឿងញៀនឆ្លងកាត់ព្រំដែនរវាងខេត្តទាំងពីរ ។

*៥. កិច្ចសហប្រតិបត្តិការអន្តរជាតិ*

ដើម្បីចូលរួមចំណែកក្នុងយន្តការត្រួតពិនិត្យគ្រឿងញៀនទ្វេភាគី ពហុភាគីជាមួយបណ្តាប្រទេសនៅក្នុង អនុតំបន់ តំបន់ និងអន្តរជាតិ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនបានចាត់បញ្ជូនមន្ត្រីជំនាញទៅចូលរួម នៅក្នុងសិក្ខាសាលា វគ្គបណ្តុះបណ្តាល កិច្ចប្រជុំ ទស្សនកិច្ចសិក្សា នានា ជាអាទិ៍ ៖

-បានចាត់មន្ត្រីជាន់ខ្ពស់របស់ អជបគញ ចំនួន ២ រូប ទៅចូលរួមក្នុងកិច្ចប្រជុំអន្តរក្រសួងដើម្បីរៀបចំ ខ្លឹមសារកិច្ចប្រជុំគណៈកម្មការចម្រុះសហប្រតិបត្តិការទ្វេភាគី កម្ពុជា-ថៃ លើកទី៧ កាលពីថ្ងៃទី០៥ខែ មករាឆ្នាំ២០១១ នៅក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ(កិច្ចប្រជុំនេះនឹងត្រូវប្រារព្ធធ្វើនៅ ថ្ងៃទី៣-៤ខែកុម្ភៈឆ្នាំ២០១១) ។

-បានបង្កើតក្រុមការងារសម្រាប់តាក់តែងផែនការសកម្មភាពគំរោងទ្វេភាគីកម្ពុជា ជាមួយអគ្គរដ្ឋអាជ្ញានៃ សាធារណរដ្ឋកូរ៉េ តាមរយៈទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉េ(*KOICA*) ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងបានរៀបចំលិខិតជាផ្លូវការស្នើសុំទៅរដ្ឋាភិបាលនៃសាធារណរដ្ឋកូរ៉េ ។

-បានស្នើសុំគោលការណ៍អនុញ្ញាតឲ្យអង្គការ*UNODC* ជួយបង្កើតការិយាល័យទំនាក់ទំនងព្រំដែន(*BLO*) ចំនួនពីរកន្លែងនៅច្រកទ្វារអន្តរជាតិភ្នំដិន ខេត្តតាកែវ(ជាប់ជាមួយខេត្តអានយ៉ាង ប្រទេសវៀតណាម) និងច្រកទ្វារអន្តរជាតិត្រពាំងផ្លុង ខេត្តកំពង់ចាម(ជាប់ជាមួយខេត្តតៃនិញ ប្រទេសវៀតណាម) ។

## III. ការសន្និដ្ឋាន និង វាយតម្លៃ

ក្នុងខែមករានេះ

តាមសភាពការណ៍ដូចដែលបានបង្ហាញពីខាងដើមនិងលទ្ធផលនៃការងារបង្ក្រាបបទ ល្មើស យើងបានវាយតម្លៃថា ដោយសារបណ្តាប្រទេសនៅក្នុងតំបន់និងអន្តរជាតិ ជាពិសេសបណ្តាប្រទេស ដែលជាប្រភពឧស្សាហកម្មគីមីបានយកចិត្តទុកដាក់ពង្រឹងយន្តការត្រួតពិនិត្យតាមដាននូវការផលិត ការចរាចរ និងការប្រើ ប្រាស់សារធាតុគីមីផ្សំ រួមគ្នារវាងរដ្ឋាភិបាលនិងឯកជន បានធ្វើឲ្យក្រុមឧក្រិដ្ឋជនជួបការលំបាកក្នុង ការបង្វែរសារធាតុគីមីផ្សំគ្រឿងញៀនយកទៅផលិតជាគ្រឿងញៀនខុសច្បាប់ ។ ដូច្នេះតម្រូវការសារធាតុគីមីផ្សំ ចាំបាច់មួយចំនួនដូចជា អេហ្វេទ្រីន និង ផ្សឺដូ-អេហ្វេទ្រីន ដែលជាវត្ថុធាតុដើមដ៏សំខាន់ក្នុងការផលិតគ្រឿងញៀន*ATS* ត្រូវបានក្រុមឧក្រិដ្ឋជនព្យាយាមរិះរកតាមគ្រប់វិធីដើម្បីផ្គត់ផ្គង់ឲ្យការផលិត ។ នេះជាបញ្ហាដែលជះ ឥទ្ធិពលដល់កម្ពុជា ដែលជាប្រទេសមិនទាន់មានបទពិសោធន៍គ្រប់គ្រាន់ក្នុងការងារត្រួតពិនិត្យសារធាតុគីមីផ្សំគ្រឿងញៀន ដែលទាមទារត្រូវមានការពង្រឹងសមត្ថភាពដល់មន្ត្រីអនុវត្តច្បាប់ រួមទាំងការបំពាក់នូវឧបករណ៍ សម្ភារៈ បច្ចេកវិទ្យាទំនើបក្នុងការត្រួតពិនិត្យសារធាតុគីមីផ្សំគ្រឿងញៀន និងកិច្ចសហប្រតិបត្តិការក្នុងការផ្តល់ ព័ត៌មានឲ្យបានទាន់ពេលវេលាជាមួយបណ្តាប្រទេសពាក់ព័ន្ធនានា ។

## IV. ទិសដៅការងារត្រួតពិនិត្យគ្រឿងញៀន ខែកុម្ភៈ ឆ្នាំ២០១១

សេចក្តីដូចបានធ្វើការសន្និដ្ឋាន និងវាយតម្លៃអំពីសភាពការណ៍គ្រឿងញៀន និងចំណុចប្រឈមក្នុងការ អនុវត្តន៍យុទ្ធសាស្ត្រខាងលើ អាជ្ញាធរជាតិបានដាក់ចេញនូវទិសដៅដើម្បីអនុវត្តន៍បន្តដូចខាងក្រោម៖

១. ការកាត់បន្ថយតម្រូវការគ្រឿងញៀន

១.១.បន្តសហការសម្របសម្រួលជាមួយក្រសួងជាសមាជិក អ.ជ.ប.គ.ញ គណៈកម្មាធិការ ត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត ក្នុងការផ្សព្វផ្សាយអប់រំលើកកម្ពស់ការយល់ដឹងជា សាធារណៈពីគ្រោះថ្នាក់នៃគ្រឿងញៀន តាមប្រព័ន្ធផ្សព្វផ្សាយ(វិទ្យុ ទូរទស្សន៍) របស់រដ្ឋ និងឯកជន ជាពិសេស តាមកម្មវិធីប្រចាំខែដែលផ្តល់ដោយស្ថានីយទូរទស្សន៍ *CTN* ។

១.២.បន្តដឹកនាំ សម្របសម្រួល និងសហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ ជម្រុញការរៀបចំទិវា ប័ណ្ណអន្តរក្រសួង សម្រាប់ការងារផ្សព្វផ្សាយនៅតាមគោលដៅដែលងាយប្រឈមខ្ពស់នឹង គ្រោះថ្នាក់ ។

១.៣.បន្តកិច្ចដំណើរការប៉ាន់ប្រមាណពីចំនួនអ្នកប្រើប្រាស់គ្រឿងញៀននៅកម្ពុជា” ។

១.៤.បន្តការរៀបចំក្រុមប្រឹក្សាផ្តល់យោបល់ ដើម្បីគាំទ្រដល់សកម្មភាពរបស់ក្រុមការងារប៉ាន់ប្រមាណចំនួនអ្នកប្រើប្រាស់គ្រឿងញៀននៅកម្ពុជា ។

**២.ការងារព្យាបាល ស្តារនីតិសម្បទា និង ការកាត់បន្ថយគ្រោះថ្នាក់**

**២.១. ការងារព្យាបាល និង ស្តារនីតិសម្បទា**

២.១.១.បន្តជម្រុញការងារសាងសង់មជ្ឈមណ្ឌលជាតិព្យាបាល និង ស្តារនីតិសម្បទា អ្នក ញៀនគ្រឿងញៀននៅខេត្តព្រះសីហនុ ។

២.១.២.សម្របសម្រួលជាមួយក្រសួងពាក់ព័ន្ធ ដើម្បីជម្រុញការតាក់តែងប្រកាស និងអនុ ក្រឹត្យ ដូចមានចែងក្នុងមាត្រា៣ មាត្រា៤ និងមាត្រា៦ នៃអនុក្រឹត្យស្តីពីការបង្កើត មជ្ឈមណ្ឌលជាតិព្យាបាលនិងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ។

***២.២. ការកាត់បន្ថយគ្រោះថ្នាក់***

២.២.៣.ត្រួតពិនិត្យតាមដានការអនុវត្តន៍កម្មវិធីម្ជុល/ស៊ីរ៉ាំង ដែលបានអនុញ្ញាតឲ្យអង្គការមិន មែនរដ្ឋាភិបាលមួយចំនួនអនុវត្ត ។

**៣.ការកាត់បន្ថយការផ្គត់ផ្គង់គ្រឿងញៀន**

៣.១. ត្រៀមបទឧទ្ទេសនាមក្នុងវគ្គបណ្តុះបណ្តាលរួម របស់មន្ត្រីនគរបាលជាន់ខ្ពស់អាស៊ាន លើកទី១០(*JASPOC*)ស្តីពីសភាពការណ៍និងស្ថានភាពច្បាប់ប្រឆាំងការជួញដូរគ្រឿង ញៀននៅកម្ពុជា នៅមជ្ឈមណ្ឌលប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែន នាថ្ងៃទី២២ខែកុម្ភៈឆ្នាំ ២០១១ ។

៣.២. បន្តកិច្ចសហការក្នុងការរៀបចំកម្មវិធីបង្រៀន សម្រាប់វគ្គបណ្តុះបណ្តាលសមត្ថភាពមន្ត្រី អនុវត្តច្បាប់ ។

៣.៣. បន្តការបើកវគ្គបណ្តុះបណ្តាលមន្ត្រីអនុវត្តច្បាប់ស្តីពី “ការងារត្រួតពិនិត្យគ្រឿងញៀន និងការកាត់បន្ថយគ្រោះថ្នាក់” ។

***៤.កិច្ចសហប្រតិបត្តិការអន្តរជាតិ***

៥.១.ត្រៀមទៅចូលរួមសន្និសីទ ស្តីពីកិច្ចសហប្រតិបត្តិការអនុវត្តច្បាប់គ្រឿងញៀននៅតំបន់អាស៊ី- ប៉ាស៊ីហ្វិក

លើកទី១៦(*ADEC*)នៅក្រុងតូក្យូប្រទេសជប៉ុន ថ្ងៃទី២២-២៤ខែកុម្ភៈឆ្នាំ២០១១។

៥.២.ត្រៀមចូលរួមក្នុងកិច្ចប្រជុំគណៈកម្មការចម្រុះសហប្រតិបត្តិការទ្វេភាគីកម្ពុជា-ថៃលើកទី៧ដែល នឹងប្រព្រឹត្តទៅនៅថ្ងៃទី៣-៤ខែកុម្ភៈឆ្នាំ២០១១) ។

៥.៣.បន្តការរៀបចំផែនការសកម្មភាពគំរោងទ្វេភាគីកម្ពុជា-កូរ៉េ ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

.ការអនុវត្តន៍គោលការណ៍ប្រៀបសមរភូមិប្រឆាំងបទល្មើសគ្រឿងញៀន

ដើម្បីអនុវត្តបានសម្រេចទិសដៅត្រួតពិនិត្យគ្រឿងញៀនខាងលើ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន នឹងបន្តជម្រុញការអនុវត្តន៍គោលការណ៍ប្រៀបសមរភូមិប្រឆាំងបទល្មើសគ្រឿងញៀន ដោយផ្តោតសំខាន់លើ ៖

-ការជម្រុញការរៀបចំយន្តការបង្កើត សាលារៀនពណ៌បៃតងគំរូគ្មានគ្រឿងញៀន ។

-ការជម្រុញការរៀបចំប្រព័ន្ធទិន្នន័យព័ត៌មានគ្រឿងញៀន ថ្នាក់ជាតិ ។

-ការជម្រុញការរៀបចំផែនការជាតិ៥ឆ្នាំ(២០១១-២០១៥) ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដើម្បីដាក់ឆ្លងសម័យប្រជុំអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ។

-ការជម្រុញការរៀបចំកិច្ចប្រជុំបូកសរុបការងារប្រមូលទិន្នន័យព័ត៌មានគ្រឿងញៀន តាមគោលការណ៍ ប្រៀបសមរភូមិប្រយុទ្ធប្រឆាំងបទល្មើសគ្រឿងញៀន ។

-ការដកពិសោធន៍លើការអនុវត្តន៍ផែនការប្រតិបត្តិត្រួតពិនិត្យគ្រឿងញៀននៅខេត្តបន្ទាយមានជ័យ ។

អគ្គលេខាធិការស្តីទី

ចម្លងជូន

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

-ខុទ្ទកាល័យ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី កែ គឹមយ៉ាន

-ឯកឧត្តម កៅ ខុនដារ៉ា អនុប្រធាន អជបគញ

“ដើម្បីជូនជ្រាប”

-ក្រសួងសមាជិក អជបគញ

-ក្រសួងផែនការ

-គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀន រាជធានី-ខេត្ត

-នាយកដ្ឋាន សរុប នៃទីស្តីការគណៈរដ្ឋមន្ត្រី

“ដើម្បីមុខការ”

-ឯកសារ

# អង្គភាពដែលបានធ្វើការផ្សព្វផ្សាយអប់រំ
# ពីគ្រោះថ្នាក់នៃគ្រឿងញៀន ខែ មករា ឆ្នាំ ២០១១

| ឈ្មោះអង្គភាព | ខ្លឹមសារ គោលដៅ និង សមាសភាព | ចំនួនសរុប |
|---|---|---|
| អជបគញ | -កិច្ចសហការបង្កើតខិត្តប័ណ្ណអន្តរក្រសួងផ្សព្វផ្សាយ តាមគោលដៅខាយប្រឈមគ្រោះថ្នាក់ខ្ពស់<br>-ការបញ្ច្រាបកម្មវិធីអប់រំបង្ការគ្រឿងញៀន នៅក្នុងទិវា ៧ មករា ២០១១ (អ្នកចូលរួមប្រមាណ ៥០០ នាក់)<br>-ការជួយធ្វើអន្តរាគមន៍ទៅខេត្តបាត់ដំបង បន្ទាយមានជ័យ សៀមរាប ភ្នំពេញ ឲ្យសមាគមយុវជនខ្មែរ បានធ្វើសកម្មភាពអប់រំ<br> បង្ការគ្រឿងញៀន<br>-ការចូលរួមជាវាគ្មិន ក្នុងនាទី វេទិកាអ្នកស្តាប់វិទ្យុអាស៊ីសេរី (កម្មវិធីសំណួរ-ចម្លើយ) | *៥០០ នាក់* |
| ខេត្តបាត់ដំបង<br>ស្រុកថ្មគោល ស្រុកបវេល | ការយល់ដឹងពីគ្រោះថ្នាក់នៃគ្រឿងញៀន និងជម្ងឺអេដស៍/មេរោគអេដស៍ ដល់ក្រុមប្រឹក្សាឃុំ លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស<br>ប្រជាពលរដ្ឋ នៅ ស្រុកថ្មគោល(១៥១នាក់), ស្រុកបវេល(១១៤ នាក់), ស្រុកភ្នំព្រឹក(៣៣៩ នាក់), | ៦០៤ នាក់ |
| ខេត្តប៉ៃលិន ក្រុងប៉ៃលិន | ការយល់ដឹងពីគ្រោះថ្នាក់នៃគ្រឿងញៀន និងជម្ងឺអេដស៍/មេរោគអេដស៍ ដល់ប្រជាពលរដ្ឋ នៅ ក្រុងប៉ៃលិន(២៩ នាក់) | ២៩ នាក់ |
| ខេត្តកំពង់ចាម ស្រុកត្បូងឃ្មុំ | ការយល់ដឹងពីគ្រោះថ្នាក់នៃគ្រឿងញៀន និងជម្ងឺអេដស៍/មេរោគអេដស៍ ដល់ប្រជាពលរដ្ឋ នៅ ស្រុកត្បូងឃ្មុំ(១៤៩ នាក់) | ១៤៩ នាក់ |
| ខេត្តកំពង់ធំ<br>ស្រុកបារាយណ៍<br>ស្រុកប្រាសាទបល្ល័ង្គ | ការយល់ដឹងពីគ្រោះថ្នាក់នៃគ្រឿងញៀន និងជម្ងឺអេដស៍/មេរោគអេដស៍ ដល់ប្រជាពលរដ្ឋ លោកគ្រូ អ្នកគ្រូ សិស្ស នៅ ស្រុកបារាយណ៍(៦៤២នាក់), ស្រុកប្រាសាទបល្ល័ង្គ (៤៧៥ នាក់), | ១.១១៧ នាក់ |
| ខេត្តកំពង់ឆ្នាំង<br>ស្រុកបរិបូណ៌ | ការយល់ដឹងពីគ្រោះថ្នាក់នៃគ្រឿងញៀន និងមេរោគអេដស៍/ជម្ងឺអេដស៍ ដល់ ប្រជាពលរដ្ឋ នៅ ស្រុកបរិបូណ៌(១៥ នាក់), | ១៥ នាក់ |
| ខេត្តព្រះវិហារ<br>ក្រុងព្រះវិហារ | ការយល់ដឹងពីគ្រោះថ្នាក់នៃគ្រឿងញៀន និងជម្ងឺអេដស៍/មេរោគអេដស៍ ដល់ ប្រជាពលរដ្ឋ(៩០ នាក់) | ៩០ នាក់ |
| ខេត្តស្វាយរៀង<br>ក្រុងស្វាយរៀង<br>ក្រុងបាវិត | ការយល់ដឹងពីគ្រោះថ្នាក់នៃគ្រឿងញៀន និងជម្ងឺអេដស៍/មេរោគអេដស៍ ដល់ក្រុមប្រឹក្សាឃុំ គណៈអភិបាលឃុំ មេភូមិ នគរ<br>បាលប៉ុស្តិ៍រដ្ឋបាល ប្រជាពលរដ្ឋ ក្រុងស្វាយរៀង(៤៣១ នាក់), ក្រុងបាវិត(១៥២ នាក់), ស្រុករំដួល(១៣៩ នាក់) | ៧២២ នាក់ |
| ខេត្តកែប ក្រុងកែប | ការយល់ដឹងពីគ្រោះថ្នាក់នៃគ្រឿងញៀន ដល់ប្រជាពលរដ្ឋ នៅក្រុងកែប(៤៥ នាក់) | ៤៥ នាក់ |
| **សរុប** | | ៣.៧៧១ នាក់ |

# អង្គភាពបង្ក្រាបបទល្មើសគ្រឿងញៀន ក្នុងខែមករា ឆ្នាំ២០១១

| ល.រ | អង្គភាព | សរុបរួម | ផលិតចរាចរជួញដូរចែក | ប្រើប្រាស់គ្រឿងញៀន | ចាប់តាមដីកា |
|---|---|---|---|---|---|

| | | | | | ចាយ | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ករណី | សរុប | ស្រី | ករណី | សរុប | ស្រី | ករណី | សរុប | ស្រី | ករណី | សរុប | ស្រី |
| *1* | មន្ទីរប្រឆាំងគ្រឿងញៀន | 6 | 21 | 6 | *6* | *21* | *6* | | | | | | |
| *2* | ន.ប ភ្នំពេញ | 11 | 16 | 2 | *10* | *13* | *2* | *1* | *3* | *0* | | | |
| *3* | ន.ប កំពង់ស្ពឺ | 0 | 1 | 0 | | | | | | | *0* | *1* | *0* |
| *4* | ន.ប កំពង់ចាម | 2 | 2 | 0 | *2* | *1* | *0* | | | | *0* | *1* | *0* |
| *5* | ព្រះសីហនុ | 2 | 5 | 2 | *2* | *5* | *2* | | | | | | |
| *6* | ន.ប ស្វាយរៀង | 1 | 2 | 1 | *1* | *2* | *1* | | | | | | |
| *7* | ន.ប ស្ទឹងត្រែង | 1 | 2 | 0 | *1* | *2* | *0* | | | | | | |
| *8* | ន.ប ព្រះវិហារ | 1 | 0 | 0 | *1* | *0* | *0* | | | | | | |
| *9* | ន.ប បាត់ដំបង | 1 | 1 | 0 | *1* | *1* | *0* | | | | | | |
| *10* | ន.ប បន្ទាយមានជ័យ | 7 | 16 | 4 | *7* | *16* | *4* | | | | | | |
| *11* | ន.ប ពោធិសាត់ | 1 | 0 | 0 | *1* | *0* | *0* | | | | | | |
| សរុប | | 33 | 66 | 15 | *32* | *61* | *15* | *1* | *3* | *0* | *0* | *2* | *0* |

## វត្ថុតាងចាប់យក រាយតាមអង្គភាព ក្នុងខែ មករា ឆ្នាំ២០១១

| លរ | ឈ្មោះអង្គភាព | វត្ថុតាងចាប់យក | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | | *WY* (គ្រាប់) | *ICE* (ក្រាម) | *Heroine* (ក្រាម) | អ៊ិចស្តាស៊ី | អេហ្វេឌ្រីន (ក្រាម) | កញ្ឆា | ប្រេងម្រះព្រៅភ្នំ | | |
| *1* | មន្ទីរប្រឆាំងគ្រឿងញៀន | *8.076* | *204* | | *7* | *3.046* | | | | |
| *2* | ន.ប ភ្នំពេញ | *212* | *4,34* | | | | | | | |
| *3* | ន.ប ស្វាយរៀង | | *1,50* | | | | | | | |
| *4* | ន.ប ស្ទឹងត្រែង | *19* | *2* កញ្ចប់តូច | | | | | | | |
| *5* | ន.ប កំពង់ចាម | *14* | | | | | *22* ដើម | | | |
| *6* | ន.ប ព្រះសីហនុ | *6* | *3,12* | | | | | | | |
| *7* | ន.ប ព្រះវិហារ | | | | | | *92* ដើម | | | |
| *8* | ន.ប បាត់ដំបង | *40* | | | | | | | | |
| *9* | ន.ប បន្ទាយមានជ័យ | *82* | | | | | | | | |
| *10* | ន.ប ពោធិ៍សាត់ | | | | | | | ៤៣៤ គ.ក្រ | | |
| | **សរុប** | ***8.449*** | ***212,96 g*** ***2* កញ្ចប់តូច** | | *7* | *3.046* | ***114* ដើម** | ***434* គ.ក្រ** | | |

**វត្ថុតាងផ្សេងៗ រថយន្ត ៧ គ្រឿង, ម៉ូតូ ៤ គ្រឿង ។**

# ទិន្នន័យសារធាតុគីមីផ្សំមានអាជ្ញាប័ណ្ណនាំចូល

| ឈ្មោះសារធាតុគីមី | អាជ្ញាបណ្ណ័ ក្រសួងឧស្សាហកម្ម | | | អាជ្ញាបណ្ណ័ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | | | សរុប | | |
|---|---|---|---|---|---|---|---|---|---|
| | Kg | L | Amp | Kg | L | Amp | Kg | L | Amp |
| Acetone | 14.400 | | | | | | **14.400** | | |
| Ethyl Acetate | 5.400 | | | | | | **5.400** | | |
| Methyl Ethyl Ketone | 18.150 | | | 30.000 | | | **48.150** | | |
| Toluene | 85.500 | | | 30.000 | | | **115.500** | | |
| Xylene | 54.500 | | | | | | **54.500** | | |
| Thinner | 135.200 | | | | | | **135.200** | | |
| Methyl Ethyl Chloride | | | | 84.000 | | | **84.000** | | |
| Sulfuric Acid | | | | | 250 | | | **250** | |
| Total | **313.150** | | | **144.000** | **250** | | **457.150** | **250** | |